ក្រសួងអប់រំរដ្ឋ NSW

# កិច្ចការដើម្បីបំពេញនៅផ្ទះ

## ព័ត៌មានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ

ដើម្បីពង្រឹងពីអ្វីដែលពួកគេកំពុងរៀនសូត្រនៅសាលា កូនរបស់អ្នកនឹងទទួលបានកិច្ចការដែលពួកគេប្រហែលជាចង់បំពេញនៅផ្ទះ។

លើកទឹកចិត្តកូនរបស់អ្នកឱ្យបំពេញកិច្ចការ ហើយនិយាយជាមួយពួកគេអំពីកិច្ចការរបស់ពួកគេ។ ការគាំទ្រកូនរបស់អ្នកតាមរបៀបនេះ ផ្តល់ឱ្យអ្នកនូវការយល់ដឹងអំពីអ្វីដែលពួកគេកំពុងរៀនសូត្រនៅសាលា ហើយបង្ហាញពួកគេថាអ្នកឱ្យតម្លៃលើការអប់រំ និងការរៀនសូត្រ។

ការបំពេញកិច្ចការនៅផ្ទះ នឹងផ្តល់ឱកាសឱ្យកូនរបស់អ្នកដើម្បី៖

- ពិនិត្យឡើងវិញនូវអ្វីៗដែលពួកគេបានរៀនសូត្រនៅសាលា
- ពង្រឹងការយល់ដឹង និងជំនាញរបស់ពួកគេ
- អភិវឌ្ឍជំនាញសិក្សាដែលពួកគេនឹងប្រើប្រាស់ពេញមួយជីវិតរបស់ពួកគេ។

### ការបង្កើតទម្លាប់ល្អៗនៅផ្ទះ

ការមានទម្លាប់ល្អ នឹងជួយកូនរបស់អ្នកពេញមួយជីវិតសិក្សា និងការងាររបស់ពួកគេ។

- កំណត់ពេលវេលាទៀងទាត់ដើម្បីបំពេញកិច្ចការ – នេះគួរតែជាពេលវេលាស្រដៀងគ្នារៀងរាល់ថ្ងៃ។
- ជ្រើសរើសពេលវេលាដែលដំណើរការល្អបំផុតសម្រាប់កូនរបស់អ្នក (កុមារខ្លះផ្តោតអារម្មណ៍បានល្អនៅពេលព្រឹក ខ្លះនៅពេលរសៀល)។

កូនរបស់អ្នកនឹងឃើញថាវាងាយស្រួលជាង ប្រសិនបើពួកគេមានកន្លែងមួយដែលមានផាសុខភាព។

- រៀបចំឱ្យមានកន្លែងមួយដែលស្ងាត់ ហើយមានពន្លឺគ្រប់គ្រាន់សម្រាប់កូនរបស់អ្នកធ្វើការ។
- មានរបស់ដែលគេត្រូវការនៅក្បែរ ដូចជាខ្មៅដៃ ក្រដាស ឬកុំព្យូទ័រ។
- ស្វែងរកកន្លែងដែលគ្មានការរំខាន (ឧទាហរណ៍ ឆ្ងាយពីទូរទស្សន៍ ឬហ្គេមកុំព្យូទ័រ)។

### តើខ្ញុំអាចជួយកូនរបស់ខ្ញុំដោយរបៀបណា?

- ចង់ដឹងចង់ឃើញ ហើយសួរសំណួរនានាអំពីអ្វីដែលពួកគេកំពុងធ្វើ។
- សុំឱ្យពួកគេបង្រៀនអ្នកពីអ្វីដែលពួកគេកំពុងរៀនសូត្រ។
- ពិនិត្យមើលថាតើពួកគេត្រូវការជំនួយដែរឬទេ។
- សរសើរចំពោះការខិតខំប្រឹងប្រែងរបស់ពួកគេ នៅពេលពួកគេព្យាយាម និងបំពេញកិច្ចការ។
- សួរគ្រូដើម្បីចូលប្រើប្រាស់ធនធានដែលមាន ដែលគាំទ្រឪពុកម្តាយ និងអ្នកថែទាំ។

សូមចងចាំថា ការបំពេញកិច្ចការនៅផ្ទះ គួរតែជាបទពិសោធន៍វិជ្ជមានមួយសម្រាប់កូនរបស់អ្នក។

អនុញ្ញាតឱ្យគ្រូដឹងថាតើកូនរបស់អ្នកត្រូវការជំនួយបន្ថែម ឬការកែតម្រូវជាក់លាក់ដើម្បីបំពេញកិច្ចការដែរឬទេ។

### សេវាអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងមកសាលារៀន សូមហៅទូរសព្ទលេខ 131 450 ប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។